**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:៣៩
ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០០៥
**សាលដីកា**
លេខ:២១២
ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ............ ជាប្រធាន
២-លោក .............. ជាចៅក្រម
៣-លោក ................ ជាចៅក្រម
៤-លោក ................ ជាចៅក្រមរបាយការណ៍
៥-លោក .................. ជាចៅក្រម

**ក្រឡាបញ្ជី**

-លោក ....................

**តំណាងមហាអយ្យការ**

-លោក ................ ជា ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ២២៤(ឈ)ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២៥៧ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ រវាង

ដើមចោទឈ្មោះ ទរន (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៦០ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន ទីលំនៅភូមិទ្រាសាទ ឃុំកំពង់ក្តី ស្រុកជីក្រែង ខេត្តសៀមរាប ។

មានមេធាវីអ្នកស្រី .......... .

ចុងចម្លើយឈ្មោះកជ (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិខ្មែរមុខរបរព្រះសង្ឃ ទីលំនៅភូមិថ្មី ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប ។

មានមេធាវីលោក........... .

តតិយជនឈ្មោះសវ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៦ឆ្នាំ ជាតិខ្មែរមុខរបរនៅផ្ទះ ទីលំនៅភូមិថ្មី ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប ។

មានមេធាវិអ្នកស្រី...........

**កម្មវត្ថុបណ្តឹង:** ប្តឹងទាមទារសុំចែកដីទិញរួមគ្នា

បានឃើញបណ្តឹងសាទុក្ខលេខ៥២៩ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៨ របស់ឈ្មោះសែម វិច ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២២៤(ឈ) ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៩ចុះថ្ងៃទី១៤ខែកុម្ភៈ ឆ្នាំ២០០៥ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៧-០៨-២០០៣ របស់ដើមចោទឈ្មោះនួន រ៉ានី ប្តឹងសុំចែកដីទំហំ១៨ម x២៩ម ស្ថិតនៅភូមិចុងកៅស៊ូ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប មានព្រំខាងជើងទល់ដីលី ទី ខាងត្បូងទល់ដីសុវណ្ណគីរី និងដី យូ ដារ៉ា និងខាងកើតទល់ដីឈ្មោះភាព ខាងលិចទល់ដីផ្លូវលំ ជាមួយឈ្មោះកជ ដោយសំអាងហេតុថាខ្លួនបានឈ្មោះកជ ជាប្តីនៅឆ្នាំ១៩៩៣ ។ នៅឆ្នាំ១៩៩៤ ខ្លួន និងឈ្មោះកជ បានចូលហ៊ុនគ្នាទិញដីនេះតម្លៃ៥ជីហ៊ុ៥នមាស ពេលនោះឈ្មោះកជ មានប្រាក់តែ១ជី៨ហ៊ុនមាសទេ ក្រៅពីនោះខ្លួនចេញទាំងអស់ នៅឆ្នាំ១៩៩៧ ខ្លួនបានចាក់ដីបំពេញអស់ប្រាក់១៤ជីមាស ពេលនោះឈ្មោះកជ មានវ័យចាស់ បានបួសជាព្រះសង្ឃ ។ ដីដែលខ្លួនបានទិញជាមួយកជ ត្រូវបានកូនស្រីរបស់គាត់មកសង់រោង ធ្វើការរ៉េម ដោយគ្មានការព្រមព្រៀងពីខ្លួនទេ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ២៤២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

របស់ដើមចោទ ទុកជាត្រឹម ត្រូវតាមទំរង់ និងគតិច្បាប់ ។

១-ក ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៧-០៨-០៣ របស់ដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

ខ-ទទួលយកសំណូមពររបស់ដើមចោទប្តឹងសុំឲ្យរុះរើរោងចេញ ទុកជាត្រឹត្រូវតាមទម្រង់ និងគតិច្បាប់ តែបដិសេធចោល ប្តឹងទាមទារជម្ងឺចិត្តដោយផ្ទុយនឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងតែបចុះថ្ងៃទី១៤-០៨-២០០៣ របស់តតិយជនទុកជាត្រឹមត្រូវតាមទម្រង់ តែត្រូវបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

៣-ប្រគល់ដីទំហំ១៣ម៉ែត្រ គុណ និង២៩ម៉ែត្រ មានព្រំខាងជើងទល់ដីឈ្មោះកជ ខាងត្បូងទល់ដីយ៉ូដារ៉ា និងហេង សុវណ្ណគីរី ខាងកើតទល់ដីភាព និង ខាងលិចទល់ ផ្លូវ ស្ថិតនៅភូមិចុងកៅស៊ូ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ទៅឈ្មោះនួន រ៉ានី ជាដើមចោទ និងប្រគល់ដីទំហំ៥ម៉ែត្រ គុណនឹង២៩ម៉ែត្រ មានព្រំខាងជើងទលំដី លី ទី ខាងត្បូង ទល់ដីនួន រ៉ានី ខាងកើតទល់ដីភាព និងខាងលិចទល់ផ្លូវលំ ស្ថិតនៅភូមិចុងកៅស៊ូដែរ ឱ្យទៅ ឈ្មោះកជ ជាចុងចម្លើយ តាមការព្រមព្រៀងរបស់ដើមចោទ និងចុងចម្លើយ ។

៤-សម្រេចឱ្យឈ្មោះសែម វិច និងកូន រុះរើរោងចេញពីដីរបស់ដើមចោទ ។

៥-បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥០០០៛ បូករួម ៧០០០៛ ។ ប្រាក់នេះចុះកាត់យកពីប្រាក់៧០០០៛ ដែលដើមចោទបានបង់ទុករួចហើយ កាលបើហួសឧទ្ធរណ៍ ត្រូវបង្គាប់ឱ្យឈ្មោះកជ បង់ពន្ធសមាមាត្រមួយភាគរយលើតម្លៃដីបន្ថែមទៀត ដែលត្រូវដាក់ ចូលថវិការដ្ឋ៨០% និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។ ពន្ធសមាមាត្រនេះត្រូវបង្គាប់ឱ្យ ដើមចោទបង់ទុកមុនដែរ ទើបបង្គាប់ឱ្យចុងចំម្លើយសងប្រាក់នេះទៅដើមចោទវិញជាក្រោយ ។

៦-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍កំណត់ពីខែ គិតពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៦០ ចុះថ្ងៃទី០៨-១២-០៣ របស់ឈ្មោះសែម រិច ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ២៤២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ របស់តុលាការ ខេត្តសៀមរាប-ឧត្តមានជ័យ ត្រង់ចំណុចសេចក្តីវិនិច្ឆ័យទាំងមូលនៃសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះនួន ប៉ានី ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ២៤២ ចុះថ្ងៃទី២៤ខែតុលា ឆ្នាំ២០០៣ របស់តុលាការ ខេត្តសៀមរាប-ឧត្តរមានជ័យ ត្រង់ចំណុចលេខរៀងទី១ ចំណុច(ខ)នៃឃ្លាចុងក្រោយនៃសេចក្តី សម្រេចថា បដិសេធចោលការប្តឹងទាមទារជម្ងឺចិត្ត ដោយផ្ទុយនឹងគតិច្បាប់ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១០០(ឈ) ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨-១២-២០០៣ របស់ឈ្មោះសែម រិច ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៨-១២-២០០៣ របស់ឈ្មោះនួន ប៉ានី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ២៤២ ចុះថ្ងៃទី២៤-១៦-២០០៣ របស់តុលាការខេត្តសៀមរាប ឧត្តរមាន់ជ័យ ទុកជាបានការដដែល ។

៤-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ គឺពន្ធហ្នឹង និងពន្ធចុះបញ្ជីក្តីចំនួន ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០៛ ចំណាយលើការប្រគល់ដីកាកោះចំនួន៥០០០៛ និងអាជ្ញាធរតុលាការចំនួន៥.០០០៛ សរុប ១៣.០០០៛ ។

៥-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៦-១៧-២០០៤ ចំពោះមុខគូក្តី កំបាំងមុខតតិយជន និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧-០៧-២០០៤ កំបាំងមុខគូក្តី និងតតិយជន តែទុកជាចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ១២៦ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៤ របស់មេធាវីល្លួង សុខា ប្តឹង មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១០០(ឈ) ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២២៤(ឈ) ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី០៥-១០-២០០៤ របស់លោកមេធាវីល្លួង សុខា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ១០០(ឈ)ចុះថ្ងៃទី២៨-០៧-២០០៤ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី១៦-១២-២០០៤ ចំពោះមុខគូក្តី និងតតិយជន និងប្រកាសជាសាធារណៈនៅថ្ងៃទី២១-១២-២០០៤ ចំពោះមុខចុងចម្លើយ និងតតិយជន កំបាំងមុខដើមចោទ តែទុកជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៥៦៩ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ របស់ឈ្មោះសែម រិច ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២២៤(ឈ) ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះសវ ។

បានឃើញសារណាតបចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥ របស់មេធាវីឈ្មោះណោតថាវរី ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា:សាលដីកាសាលាឧទ្ធរណ៍លេខ២២៤(ឈ) ចុះថ្ងៃទី២១-១២-២០០៤ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ និងគតិច្បាប់ ។

សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះសែម រិច នាពេលសវនាការថា : កាលពីទិញដីប្តីខ្លួនយកលុយពីផ្ទះទៅទិញដីចូលគ្នាជាមួយនួន រ៉ានី ម្នាក់ពាក់កណ្តាល និងយកប្រាក់ខែគាត់៥ឆ្នាំ ទៅចាក់ដីខ្លួនជាអ្នកទិញដីនេះ ខ្លួនមិនបានទៅទិញទេ តែគាត់ប្រាប់ខ្លួនថា អញយកលុយទៅទិញដី ។ ខ្លួនសំណូមពរ សុំយកដីពាក់កណ្តាល ។

បានស្តាប់ចម្លើយរបស់ឈ្មោះនួន រ៉ានី នាពេលសវនាការថា ប្តីខ្លួនមិនបានទិញដីចូលគ្នា ទេ គឺខ្លួនទិញតែម្នាក់ឯងទេ គ្រាន់តែខ្លួនដាក់ឈ្មោះគាត់ប៉ុណ្ណោះ ។ ប្រាក់ទិញដីគឺប្រាក់ខ្លួនទាំងអស់ ប្រគល់ឱ្យម្ចាស់ដីដោយផ្ទាល់ គឺពុំមានវត្តមានអ្នកស្រីសែម រិច ទៅជាមួយទេ ។ ដីនេះគាត់សុំខ្លួន ធ្វើការរ៉េមកី។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីមាស សុគន្ធា ការពារឱ្យតពីយជន បានលើកឡើង ថា : ក្នុងរឿងនេះ គឺជាការទាមទារដីរួម ។ លោកកជ មិនទាន់បានលែងលះជាមួយសែម វិច ទេ ហើយគាត់បានយកលុយពីប្រពន្ធទៅទិញដីជាមួយនួន វ៉ានី ។ បើនួន វ៉ានី ថាទិញដីនេះតែ ម្នាក់ឯង ចុះហេតុអ្វីបានជាគាត់ចែកដីនេះជាមួយកជ ។ នួន វ៉ានី ថា គាត់ប្រគល់លុយឱ្យម្ចាស់ ដីផ្ទាល់ ចំណែកសវ ថាកូនគាត់ ជាអ្នកប្រគល់លុយឱ្យម្ចាស់ដីដែរ ដូច្នេះសុទ្ធតែពុំមានភាពច្បាស់លាស់ដូចគ្នា ដែលទាមទារឱ្យសួរបញ្ជាក់ម្ចាស់ដី ចុះហេតុអ្វីបានជាពុំមានចម្លើយសាក្សី ដែលជាម្ចាស់ដីដែលបានលក់ដីនេះ មានន័យថា តុលាការថ្នាក់ក្រោមលប់បំបាត់សាក្សី ។

**<u>សំណូមពរ</u>** សុំបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះឡើងវិញ ព្រោះសាលាឧទ្ធរណ៍ពុំបានអង្កេតឱ្យបានច្បាស់លាស់ទេ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមចុះយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមចោទ តតិយជន និងសេចក្តីសន្និដ្ឋានរបស់មេធាវីតតិយជន
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខអ្នកស្រី សែម វិច ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន ដោយយោងតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា អ្នកស្រីសែម វិច មិនមានគុណសម្បត្តិតាមផ្លូវច្បាប់ក្នុងការទាមទារចែក ដីទំនាស់ពាក់កណ្តាល ដែលជាដីបានទិញរួមគ្នារវាងអ្នកស្រីនួន វ៉ានី និងលោកកជ ឡើយពីព្រោះថា ពុំមានភស្តុតាងណាដែលបញ្ជាក់ថា អ្នកស្រីសែម វិច បានផ្តល់ប្រាក់ឱ្យលោកកជ យកទៅទិញដីឡើយ ។

-យល់ឃើញថា តាមកំណត់ហេតុផ្សះផ្សារសំរុះសំរួលចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៣ របស់តុលាការខេត្តសៀមរាប គូភាគីបានស្រុះស្រួលគ្នាដោយលោកកជ សុខចិត្តទទួលយកដី ទំហំ៥មx ២៩មផ្នែកខាងជើងនិងសល់ប៉ុន្មានត្រូវបានទៅអ្នកស្រីនួន វ៉ានី ពីព្រោះលោកបានចេញប្រាក់តែចំនួន មួយដីប្រាំពីរហ៊ុន ក្នុងចំនួនថ្ងៃដីសរុប១៥ដី ឯការចាក់ដីបំពេញអស់១៤ដី ជាប្រាក់របស់អ្នកស្រីនួន វ៉ានី ទាំងអស់។

- យល់ឃើញថា ដោយអ្នកស្រីសែម វិច ស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ ជាមួយលោកកជ ដូច្នេះអ្នកស្រីសែម វិច មានសិទ្ធិត្រឹមតែទាមទារទ្រព្យដែលជាចំណែករបស់លោកកជ តែប៉ុណ្ណោះ ។

- យល់ឃើញថា ការដែលមេធាវីតតិយជន លើកឡើងអំពីចម្លើយសាក្សីថា ឈ្មោះកិក ម៉ាប់ ជាកូនឈ្មោះកជ ជាអ្នកប្តឹងមាសឱ្យម្ចាស់ដីនោះ ពុំអាចបដិសេធការអះអាងរបស់ម្ចាស់ដី ថា ខ្លួនពិតជាបានលក់ដីឱ្យកជ និងអ្នកស្រីនួន រ៉ានី មែននោះទេ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចឱ្យចុងចម្លើយបង់ ពន្ធសមាមាត្រនោះគឺជាការភ័ន្តច្រឡំ ពីព្រោះថា ភាគីចុងចម្លើយ និងដើមចោទបានព្រមព្រៀងគ្នារួចហើយ ប៉ុន្តែភាគីតតិយជន ដែលប្តឹងសាទុក្ខ ដោយគ្មានគុណសម្បត្តិក្នុងរឿងក្តីនេះទេ ដូច្នេះភាគីតតិយជនត្រូវទទួលខុស ត្រូវលើប្រាក់ពន្ធសមាមាត្រ ដែលគប្បីតុលាការកំពូលកែតម្រូវដោយឥតបង្អិល ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ២២៤ (ឈ) ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខដើមចោទ និងតតិជន និងមេធាវី

១-ទទួលបណ្តឹងសាទុក្ខលេខ៥២៩ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ របស់អ្នកស្រីសែម រិច ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ២២៤(ឈ) ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលដើមចោទ បានបង់ផ្ទួសគឺ :

-ពន្ធចុះបញ្ជីក្តី នឹងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជា រង្វាន់ក្រឡាបញ្ជីកាត់ហិបប្រាក់,

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

តម្រូវឱ្យអ្នកស្រីសែម រិច សងប្រាក់១៩០០០៛ ទៅដើមចោទវិញ ។

បង្គាប់ឱ្យតតិយជនខាងចុងចម្លើយ បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការ ខេត្តសៀមរាប ។,

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៦។